# វិហារវត្តមជ្ឈិមវ័ន៖ អតីតវិហារបុរាណនៃចុងសតវត្សទី១៩

វត្តមជ្ឈិមវ័ន មានទីតាំងស្ថិតនៅក្នុងសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅតាមបណ្ដោយផ្លូវជាតិលេខ១ ប្របងទន្លេមេគង្គ។ កាលដើមឡើយវត្តនេះឈ្មោះ "វត្តជ្រោយអំពិលថ្មី" ហើយគេនិទានថា វត្តនេះកកើតឡើងថ្មីក្រោយវត្តជ្រោយអំពិលដែលស្ថិតនៅក្បែរនោះ[១] លុះចំណេរតមកទើបប្ដូរឈ្មោះផ្លាស់នាមហៅ "វត្តមជ្ឈិមវ័ន"។ ប៉ុន្តែយ៉ាងណាក៏ដោយ បច្ចុប្បន្នវត្តនេះមានវិហារមួយយ៉ាងចំណាស់ ហើយធ្លាប់បានជួសជុលរៀបចំកែសម្រួលរចនាសម្ព័ន្ធស្ថាបត្យកម្មពីអតីតវិហារបុរាណ ដែលគេយល់ថាកសាងឡើងតាំងពីក្នុងរវាងចុងសតវត្សទី១៩។

វិហារបុរាណវត្តមជ្ឈិមវ័ន មានបណ្ដោយប្រហែលជាង១៥ម៉ែត្រ ទទឹងជាង៨ម៉ែត្រ សង់នៅលើខឿនកម្ពស់ប្រហែល១ម៉ែត្រ បែរទៅទន្លេ។ នៅលើវិហារនេះ គេពុំឃើញមានសំណេរណាមួយកត់ចារទុកកាលបរិច្ឆេទនៃការកសាងឡើយ។ តាមរយៈការសិក្សារបស់ *Danielle & Dominique-Pierre Guéret* យល់ថា វិហារវត្តមជ្ឈិមវ័នកសាងតាំងពីរវាងឆ្នាំ១៨៨០[២] ប៉ុន្តែមួយរយៈថ្មីៗកន្លងមកនេះ មានសារព័ត៌មានជាច្រើនចុះផ្សាយតៗគ្នាថា វិហារវត្តនេះកសាងក្នុងឆ្នាំ១៩០១។ ដូច្នេះបានសេចក្ដីថាវិហារនេះកសាងឡើងតាំងពីក្នុងរាជ្យរបស់ **ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម "ព្រះសុវណ្ណកោដ្ឋ"** ពោលគឺក្នុងកាលបរិច្ឆេទប្រហាក់ប្រហែលនឹងការកសាងវិហារបុរាណវត្តចិនដំដែក ដែលស្ថិតនៅកណ្ដាលរាជធានីភ្នំពេញដែរ។[៣]

ទោះជាបែបណាក្ដី តាមរយៈរូបថតឯកសារចាស់ជាងគេថតឆ្នាំ១៩២៩ បង្ហាញថា ទម្រង់សំណង់ដើមនៃវិហារវត្តមជ្ឈិមវ័ន ក៏ជាប្រភេទវិហារឈើជហ្វាបួន សង់នៅលើខឿនមួយថ្នាក់ ប្រភេទដំបូលកិង ប្រក់ក្បឿងស្រកាលេញរាងជ្រាលបីថ្នាក់នៅផ្នែកចំហៀងសងខាង

---

[១] សព្វថ្ងៃវត្តជ្រោយអំពិលមានវិហារថ្មី ដែលទើបកសាងពីឆ្នាំ១៩៩៧ នៅលើទីតាំងវិហារចាស់

[២] Daniel Guéret & Doninique-Pierre Guéret 2017: 96

[៣] សូមអានបន្ថែម៖ "សិល្ប: និងស្ថាបត្យកម្មនៃវិហារបុរាណវត្តចិនដំដែក" ដោយ ហៀន សុវណ្ណមរកត ផ្សាយលើគេហទំព័រ *AMS Khmer Civilization* លើតំណ [https://asset.ams.com.kh/khmercivilization/media/Wat-Chen-Damdek.pdf](https://asset.ams.com.kh/khmercivilization/media/Wat-Chen-Damdek.pdf) ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

និងរាងជ្រាលពីរថ្នាក់មុខក្រោយក្រោមហោងជាង ព្រមទាំងមានហប់ខ្យល់ចំហៀង និងដាក់តម្កល់សន្ទឹកសីមាព័ទ្ធជុំវិញផងដែរ។ ក្រោយមក គេឃើញមានតចុងដំបូលបន្ថែមជុំវិញដោយប្រើជន្ទល់ឈើភ្ជាប់នឹងសសរទ្រចុងដំបូលថ្មីនោះ។ រីឯជញ្ជាំងវិហារ គេមើលឃើញថាទំនងជាជញ្ជាំងឈើ ឬស្វាបព្រិលដែលអាចទាញបើកបិទបាន (រូបលេខ១)។ លក្ខណៈជញ្ជាំងវិហារបែបនេះ ឬវិហារឥតជញ្ជាំង គេឃើញមាននិយមតិចតួចដែរក្នុងសង្គមខ្មែរជំនាន់ដើមដូចជា វិហារបុរាណវត្តពោធិ៍ និងវិហារបុរាណវត្តស្វាយដំណាក់នៅខេត្តត្បូងឃ្មុំ និងវិហារបុរាណវត្តសំបូរ ក្នុងខេត្តកំពង់ធំជាដើម។



រូបលេខ១ ទម្រង់ដើមវិហារវត្តមជ្ឈិមវ័ន (EFEO, 1929)

ដោយឡែកចំពោះវិហារនៃអារាមវត្តមជ្ឈិមវ័ន ដែលយើងឃើញសព្វថ្ងៃ ក៏នៅតែរក្សាជាទម្រង់វិហារបុរាណដដែល តែជញ្ជាំងឥដ្ឋបូកកំបោរបាយអ និងមានសសរបេតុងជុំវិញរបៀងបាំងសាច។ នៅចុងព្រំដំបូលខាងមុខបំពាក់ជហ្វា២ ចុងព្រំដំបូលខាងក្រោយជហ្វា២ និងតាមចែងនីមួយៗលម្អដោយក្បាលនាគ (រូបលេខ២-៣)។ គេមើលឃើញថាវិហារបុរាណជហ្វា៤នេះ ជាវិហារដែលពេញនិយមបំផុតនៅដើមសតវត្សទី២០។[៤]

---

[៤] សុង សុគី ២០០៦: ១៤៩ និងព្រាប ចាន់ម៉ារ៉ា ២០១៧: ១៣-១៧

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត




រូបលេខ២-៣ ស្ថានភាពវិហារវត្តមជ្ឈិមវ័នបច្ចុប្បន្ន (រូបថតពីមុខ និងពីក្រោយ)

រីឯហោជាងទាំងពីរនៃវិហារវត្តនេះ ជាផ្ទាំងហោជាងស៊ីម៉ង់ត៍ ដែលគេរចនាលម្អដោយទម្រង់ក្បាច់ពីរផ្សេងគ្នា។ នៅលើហោជាងផ្នែកខាងមុខ គេរចនាដោយក្បាច់ភ្ញីភ្លើងបំបែកចេញពីមាត់ព្រះកាល(?) និងអមដោយក្បាច់ក្នុងលំនាំជាក្បាលនាគ។ ចំណែកឯហោជាងនៅផ្នែកខាងក្រោយ គេរចនាដោយក្បាច់អង្គរបំបែកជុំវិញនាគក្បាលបី(?) (រូបលេខ៤-៥)។




រូបលេខ៤ ហោជាងខាងមុខ

រូបលេខ៥ ហោជាងខាងក្រោយ

នៅលើជញ្ជាំងវិហារទាំងបួនទិសពុំមានបង្អួចឡើយ តែនៅផ្នែកខាងមុខមានទ្វារ៣ ខាងក្រោយមានទ្វារពីរ និងផ្នែកចំហៀងមានទ្វារម្ខាងបួនដូចគ្នា។ ទន្ទឹមនឹងនេះ នៅតាមសសរនីមួយៗនៃរបៀងបាំងសាច គេបានបំពាក់ដោយរូបគ្រុឌទ្រចុងដំបូល ដូចនៅតាមបណ្ដាវិហារផ្សេងៗដែរ (រូបលេខ៦-៧)។ ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់នៃក្បាលសសររបៀងបាំងសាចទាំងអស់ និងផ្នែកខាងលើជញ្ជាំងជុំវិញ គេពុំឃើញមានធ្នឹមក្រវាត់ភ្ជាប់គ្នាដើម្បីទ្រដំបូលឡើយ។ លើសពីនេះ ការក្រាលការ៉ូបាតជុំវិញនៃរបៀងបាំងសាចក៏មាន

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

*លក្ខណៈចម្រុះដែរ ពោលគឺពុំមែនប្រើប្រាស់ការ៉ូមួយតែមួយប្រភេទ។ លក្ខណៈនេះ ហាក់បង្ហាញឱ្យឃើញកាន់តែច្បាស់ពីការកែសម្រួលរចនាសម្ព័ន្ធវិហារចាស់ ដោយបន្ថែមសសរបេតុងនៅរបៀងបាំងសាច រៀបជញ្ជាំងឥដ្ឋ និងការ៉ូជុំវិញ (រូបលេខ៨)។ ចំពោះការលម្អនៅលើក្បាច់ស៊ុមទ្វារនីមួយៗ គេរចនាដោយក្បាច់អង្គរ ចាក់ពុម្ពពីស៊ីម៉ង់ត៍។ ប៉ុន្តែអ្វីដែលពិសេសនៅលើរចនាសម្ព័ន្ធ និងការលម្អនៅលើក្បាច់ស៊ុមទ្វារទាំងអស់ គេឃើញមានរូបព្រះពុទ្ធបដិមាតូចមួយ ឃ្លុំចីវរជិតក ទ្រង់គង់ឈរលើនាគក្បាលប្រាំ (រូបលេខ៩-១១)។ លក្ខណៈនេះ ហាក់បង្ហាញឱ្យឃើញពីការច្នៃប្រឌិតមួយនៅក្នុងសិល្បៈ។*





*រូបលេខ៦ សសរបៀងបាំងសាច  រូបលេខ៧ គ្រុឌទ្រចុងដំបូល  រូបលេខ៨ ចន្លោះរបៀងបាំងសាច*





*រូបលេខ៩-១១ ការលម្អនៅលើក្បាច់ស៊ុមទ្វារនីមួយៗ ព្រមទាំងសភាពទ្រុឌទ្រោមរចនាសម្ព័ន្ធជញ្ជាំង*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

ផ្នែកខាងក្នុងនៃវិហារ មានសសរឈើបួនជ្រុង តូចៗពីរជួរតំអមសងខាងព្រះដីរ៍ៗ នៅលើសសរនីមួយៗ គេឃើញមានស្នាមដាប់នៅលើផ្នែកចំហៀងសសរ ដើម្បីផ្ទឹមទៅនឹងសសរដើមខាងក្រៅ (រូបលេខ១២-១៣)។ ទិដ្ឋភាពត្រង់នេះ ហាក់ឆ្លើយគ្នាទៅនឹងរចនាសម្ព័ន្ធខាងក្រៅ ដែលសព្វថ្ងៃជំនួសដោយសសរបេតុងដូចបាននិយាយមកខាងលើ។ រីឯពិតាន គឺជាពិតានឈើដែលគេពុំឃើញមានស្នាកស្នាមគំនូរ ឬការលម្អអ្វីធំដុំឡើយ។



រូបលេខ១២-១៣ សសរឈើផ្នែកខាងក្នុងវិហារ និងស្នាកស្នាមដាប់លើសសរនីមួយៗ

ចំពោះព្រះដីរ៍ធំក្នុងវិហារវត្តមជ្ឈិមវ័ន គេឃើញតម្កល់នៅលើបល្ល័ង្កខ្ពស់មួយមានបួនថ្នាក់ ហើយលម្អដោយក្បាច់រចនាយ៉ាងវិចិត្រ និងរស់រវើក។ ព្រះបដិមាព្រះដីរ៍ គង់ក្នុងកាយវិហារផ្ចាញ់មារ។ នៅមុខព្រះដីរ៍ គេលម្អដោយទងក្បាច់ផារនាំង ឆ្លាក់អំពីឈើ ក្នុងលំនាំជាវល្លិ៍ ស្លឹក ផ្កា និងផ្លែនៃរុក្ខជាតិ ព្រមទាំងមានរូបសត្វស្វាបតូចធំទំប្រចឹកលេងផង (រូបលេខ១៤)។ លក្ខណៈសិល្បៈនេះ ហាក់ប្លែកនិងកម្រឃើញមាន ដែលបង្ហាញឱ្យឃើញពីទឹកដៃ និងគំនិតច្នៃប្រឌិតយ៉ាងចំណាន។ ដោយឡែក នៅតាមជញ្ជាំងផ្នែកខាងក្នុងគេពុំមានគំនូរអ្វីឡើយ ពោលគឺជាជញ្ជាំងលាត ដែលសព្វថ្ងៃគេគ្រាន់តែព្យួររូបព្រះបត់ចាស់ៗជាច្រើនផ្ទាំងសម្រាប់គោរពបូជាប៉ុណ្ណោះ (រូបលេខ១៥)៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត




*រូបលេខ១៨-១៩ ព្រះដីរ៍ និងព្រះបត់ព្យួរតាមជញ្ជាំងវិហារវត្តមជ្ឈិមវ័ន*

# ឯកសារយោង


ព្រាប ចាន់ម៉ារ៉ា

២០១៧, *សំណង់នៅតាមវត្ត*, ការផ្សាយរបស់អ្នកនិពន្ធ

សុង សុគី

២០០៦, "ការរចនាលម្អ និងស្ថាបត្យកម្មនៃព្រះវិហារឈើ៖ ការបែងចែកផ្នែកទាំងឡាយទៅតាមប្រភេទ", *សំណង់អំពីឈើនៅប្រទេសកម្ពុជា៖ កេរដំណែលដែលកំពុងសាបសូន្យ*, ទំ. ១៤៧-១៦៦, មជ្ឈមណ្ឌលខេមរសិក្សា, ភ្នំពេញ

ហៀន សុវណ្ណមរកត

២០២១, "សិល្បៈ និងស្ថាបត្យកម្មនៃវិហារបុរាណវត្តចិនដំដែក" ផ្សាយលើគេហទំព័រ *AMS Khmer Civilization* លើតំណ
https://asset.ams.com.kh/khmercivilization/media/Wat-Chen-Damdek.pdf
ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២១

Daniel Guéret & Doninique-Pierre Guéret

2017, *The Khmer Pagoda*, Kam editions


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត